**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ: ០៤៧/២០ ស.ណ.ហ

*ថ្ងៃ សុក្រ ៤ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២០*

## សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្ទេរថ្លៃសេវាប្រមូលសំរាម និងសំណល់រឹង នៅរាជធានីភ្នំពេញ ពីក្រុមហ៊ុនស៊ីនទ្រី (ខេមបូឌា) មកជូនរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ វិញ

រដ្ឋបាលរាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់គ្រប់ ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងវិស័យឯកជន ទាំងអស់ មេត្តាជ្រាបថា បច្ចុប្បន្នរដ្ឋបាលរាជធានីភ្នំពេញ បានបង្កើតរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ ដើម្បីប្រតិបត្តិការគ្រប់គ្រងការប្រមូលសំរាម និងសំណល់រឹង ក្នុងរាជធានីភ្នំពេញ បន្តពីក្រុមហ៊ុនស៊ីនទ្រី (ខេមបូឌា) ដែលរាជរដ្ឋាភិបាលកម្ពុជាបានបញ្ចប់កិច្ចសន្យា។

ដើម្បីគ្រប់គ្រងរាល់ចំណូល-ចំណាយស្របតាមនីតិវិធីហិរញ្ញវត្ថុ សូមគ្រប់ ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងវិស័យឯកជន ទាំងអស់ ដែលធ្លាប់បានទូទាត់ថ្លៃសេវាប្រមូលសំរាម និងសំណល់រឹង តាមរយៈការបោះផ្សាយអាណត្តិ ឬបង្វែរត្រង់ជូនក្រុមហ៊ុនស៊ីនទ្រី (ខេមបូឌា) សូមមេត្តារៀបចំបោះផ្សាយអាណត្តិ ឬបង្វែរត្រង់មកជូន រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ ដូចខាងក្រោម៖

១- <u>ចំពោះក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ដែលទូទាត់តាមរយៈការបោះផ្សាយអាណត្តិ៖</u>

- ឈ្មោះអគ្គគាហក : *រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ*
- អាសយដ្ឋានអគ្គគាហក : *អគារលេខ៦៩ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ*
- អាសយដ្ឋានរតនាគារ ឬធនាគារ : *រតនាគាររាជធានីភ្នំពេញ*

២- <u>ចំពោះវិស័យឯកជន ដែលទូទាត់តាមរយៈការបង្វែរ ឬទូទាត់ត្រង់៖</u>

- ឈ្មោះ : *រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ*
- គណនីប្រាក់រៀល : *0001-03-638657-23 នៅធនាគារ អេស៊ីលីដា ភីអិលស៊ី*
- គណនីប្រាក់ដុល្លារ : *0001-03-638657-13 នៅធនាគារ អេស៊ីលីដា ភីអិលស៊ី*

អាស្រ័យហេតុនេះ សូមគ្រប់ ក្រសួង អង្គភាព-ស្ថាប័នរដ្ឋ និងឯកជនទាំងអស់ មេត្តាចូលរួមសហការអនុវត្តតាមខ្លឹមសារខាងលើឲ្យមានប្រសិទ្ធភាពខ្ពស់ និងដើម្បីចូលរួមថែរក្សាអនាម័យ បរិស្ថាន និងសោភណភាពរាជធានីភ្នំពេញ ឲ្យកាន់តែស្រស់ស្អាត។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

<u>**កន្លែងទទួល៖**</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  *"ដើម្បីជូនជ្រាប"*
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ
- រតនាគារជាតិរាជធានីភ្នំពេញ
  *"ដើម្បីអនុវត្ត"*
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
  *"ដើម្បីផ្សព្វផ្សាយ"*
- ឯកសារ-កាលប្បវត្តិ

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh